Khmer/ខ្មែរ

AEC Australian Electoral Commission

# សេចក្តីណែនាំជាផ្លូវការរបស់លោកអ្នក

## អំពីការបោះឆ្នោតសហព័ន្ធ ឆ្នាំ 2019

**ថ្ងៃសៅរ៍ ទី 18 ខែឧសភា ឆ្នាំ 2019**




ការបោះឆ្នោតគឺជាការសំខាន់ចាំបាច់ដោយខានពុំបាន សម្រាប់ពលរដ្ឋអូស្ត្រាលីអាយុចាប់ពី 18 ឆ្នាំឡើងទៅ

# ថ្ងៃបោះឆ្នោតធ្វើនៅថ្ងៃសៅរ៍ ទី 18 ខែឧសភា ឆ្នាំ 2019 ។ កន្លែងបោះឆ្នោតចាប់ផ្តើមបើកពីម៉ោង៨ព្រឹក ហើយបិទនៅម៉ោង៦យប់ជាកំណត់ ។

## តើខ្ញុំអាចបោះឆ្នោតនៅកន្លែងណា?

លោកអ្នកអាចបោះឆ្នោត នៅតាមកន្លែងបោះឆ្នោតណាមួយក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នកនៅថ្ងៃបោះឆ្នោត។

ទីកន្លែងបោះឆ្នោតភាគច្រើន មានទីតាំងនៅតាមសាលារៀនក្នុងតំបន់ ព្រះវិហារ និងសាលសហគមន៍ ឬអាគារសាធារណៈ។

ដើម្បីរកកន្លែងបោះឆ្នោតដែលនៅជិតលោកអ្នកបំផុត សូមចូលមើលវិបសៃថ៍ **www.aec.gov.au/where** ។ ព័ត៌មានលម្អិតនៃកន្លែងបោះឆ្នោត ក៏នឹងត្រូវបានបោះពុម្ពផ្សាយដែរ នៅក្នុងសារព័ត៌មានធំៗរបស់ទីក្រុង មួយថ្ងៃមុនថ្ងៃបោះឆ្នោត។

លោកអ្នកអាចឆែករកមើលកន្លែងបោះឆ្នោត ដែលមានផ្លូវចេញចូលសម្រាប់មនុស្សពិការភាព នៅតាមវិបសៃថ៍ **www.aec.gov.au/where** ។

ចំពោះជម្រើសបោះឆ្នោតសម្រាប់មនុស្សខ្វាក់ ឬអន់ខ្សោយភ្នែក សូមទូរស័ព្ទលេខ 13 23 26 ។

ប្រសិនបើលោកអ្នកនឹងនៅតាមរដ្ឋផ្សេងទៀតនៅចំថ្ងៃបោះឆ្នោត លោកអ្នកអាចបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតអន្តររដ្ឋដែលបានកំណត់ ឬពិចារណាលើជម្រើសបោះឆ្នោតមុនពេលខាងក្រោមនេះ។

## ចុះប្រសិនបើខ្ញុំមិនអាចទៅកន្លែងបោះឆ្នោតបានទេ?

ប្រសិនបើលោកអ្នកមិនអាចទៅកន្លែងបោះឆ្នោត នៅថ្ងៃបោះឆ្នោតបានទេ លោកអ្នកប្រហែលជាអាចមានសិទ្ធិបោះឆ្នោតមុនពេលដោយផ្ទាល់ខ្លួន ឬតាមប្រៃសណីយ៍។

### របៀបបោះឆ្នោតមុនពេលដោយផ្ទាល់ខ្លួន

លោកអ្នកអាចបោះឆ្នោតមុនថ្ងៃបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតមុនពេលណាមួយ ជាមួយក្រុមបោះឆ្នោតចល័ត ឬនៅតាមមណ្ឌលបោះឆ្នោតអូស្ត្រាលីនៅឯបរទេស។

មណ្ឌលបោះឆ្នោតមុនពេល ចាប់បើកចាប់ពីថ្ងៃច័ន្ទ **ទី 29 ខែមេសា ឆ្នាំ** 2019 ។ កាលបរិច្ឆេទបើក និងពេលម៉ោងខុសគ្នា ដូច្នេះសូមចូលមើល **www.aec.gov.au/where** ដើម្បីពិនិត្យមើលព័ត៌មានលម្អិតអំពីមជ្ឈមណ្ឌលបោះឆ្នោតនីមួយៗ។

សម្រាប់ព័ត៌មានបន្ថែម រួមទាំងភាពមានសិទ្ធិ សូមចូលមើល **www.aec.gov.au** ឬហៅទូរស័ព្ទលេខ 13 23 26 ។

### របៀបបោះឆ្នោតមុនពេលតាមប្រៃសណីយ៍

ប្រសិនបើមានសិទ្ធិ លោកអ្នកអាចដាក់ពាក្យសុំបោះឆ្នោតតាមប្រៃសណីយ៍ តាមអនឡាញនៅត្រង់ **www.aec.gov.au/pva**។ ពាក្យសុំក៏មានផ្តល់ជូនដែរ នៅតាមការិយាល័យ AEC ណាមួយ។ សូមផ្ញើពាក្យសុំរបស់លោកអ្នកទៅ AEC ឲ្យបានឆាប់ទៅតាមលទ្ធភាព ដើម្បីឲ្យបានមកដល់យើងខ្ញុំទាន់មុនម៉ោង 6 **យប់នៅថ្ងៃពុធ ទី** 15 **ខែឧសភា ឆ្នាំ** 2019 ។

## តើមណ្ឌលបោះឆ្នោតរបស់ខ្ញុំបានផ្លាស់ប្តូរឬទេ?

បច្ចុប្បន្ននេះមានមណ្ឌលបោះឆ្នោតសហព័ន្ធចំនួន 151 (រួមទាំងមណ្ឌលពីរថ្មី)។ មណ្ឌលមួយចំនួនត្រូវបានប្តូរឈ្មោះ ហើយព្រំដែនរបស់មណ្ឌលជាច្រើន ត្រូវបានផ្លាស់ប្តូរចាប់តាំងពីការបោះឆ្នោតសហព័ន្ធចុងក្រោយ។

សូមពិនិត្យ មើលថាតើមណ្ឌលការបោះឆ្នោតមួយណាដែលលោកអ្នករស់នៅ នៅតាមវិបសៃថ៍ **www.aec.gov.au/electorate** ។

## នរណាដែលលោកអ្នកបោះឆ្នោតឲ្យនោះ គឺជាការសម្រេចរបស់លោកអ្នកទេ

នៅក្រៅកន្លែងបោះឆ្នោត អ្នកតំណាងបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រហែលជាហុចប័ណ្ណរបៀបបោះឆ្នោតជូនលោកអ្នក ដែលស្នើសុំឲ្យលោកអ្នកបោះឆ្នោត ក្នុងលំនាំជាក់លាក់មួយ។ លោកអ្នកមិនចាំបាច់ត្រូវតែទទួលយក ឬធ្វើតាមប័ណ្ណរបៀបបោះឆ្នោតទាំងនោះឡើយ។

# របៀបឲ្យគេរាប់សន្លឹកឆ្នោតរបស់លោកអ្នក

នៅថ្ងៃបោះឆ្នោត លោកអ្នកនឹងបានទទួល**សន្លឹកឆ្នោតពីរសន្លឹក**៖

- សន្លឹកឆ្នោតពណ៌បៃតង គឺសម្រាប់សភាតំណាងរាស្ត្រ ហើយ
- សន្លឹកឆ្នោតពណ៌ស គឺសម្រាប់ព្រឹទ្ធសភា។

លោកអ្នកត្រូវតែបំពេញសន្លឹកឆ្នោតទាំងពីរ។

នៅលើសន្លឹកឆ្នោតពណ៌បៃតង លោកអ្នកបោះឆ្នោតជ្រើសរើសអ្នកតំណាងតំបន់ ឬមណ្ឌលបោះឆ្នោតរបស់លោកអ្នក នៅក្នុងសភាតំណាងរាស្ត្រ។

នៅលើសន្លឹកឆ្នោតពណ៌ស លោកអ្នកបោះឆ្នោតជ្រើសរើសអ្នកតំណាងរដ្ឋ ឬដែនដីរបស់លោកអ្នក នៅក្នុងព្រឹទ្ធសភា។

**សូមកុំខ្វល់ព្រួយអ្វីឡើយប្រសិនបើលោកអ្នកបំពេញខុស។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។**

តើលោកអ្នកបានដឹងឬទេថា លោកអ្នកអាចហាត់បោះឆ្នោតនៅតាមវ៉ិបសៃថ៍ AEC? សូមចូលទៅកាន់ **www.aec.gov.au/practise-voting**

## សភាតំណាងរាស្ត្រ

នៅលើសន្លឹកឆ្នោតពណ៌បៃតង លោកអ្នកត្រូវដាក់លេខ**រៀងរាល់ប្រអប់**ទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក។




សន្លឹកឆ្នោតគំរូ

## ព្រឹទ្ធសភា

នៅលើសន្លឹកឆ្នោតពណ៌ស លោកអ្នកមានជម្រើសពីរដើម្បីបោះឆ្នោត៖

**មួយណាក៏បាន** ### នៅលើខ្សែបន្ទាត់

ប្រសិនបើលោកអ្នកជ្រើសរើសបោះឆ្នោតនៅលើខ្សែបន្ទាត់ លោកអ្នកចាំបាច់ **ត្រូវដាក់លេខឲ្យបានយ៉ាងតិច 6 ប្រអប់**។

ដាក់លេខ ‘1’ នៅក្នុងប្រអប់សម្រាប់គណៈបក្ស ឬក្រុមដែលជាជម្រើសទីមួយរបស់លោកអ្នក, ហើយដាក់លេខ ‘2’ សម្រាប់ជម្រើសទីពីររបស់លោកអ្នក ហើយជាបន្តបន្ទាប់ រហូតទាល់តែលោកអ្នកបានដាក់លេខយ៉ាងតិច 6 ប្រអប់។ លោកអ្នកអាចបន្តដាក់លេខទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក នៅក្នុងប្រអប់យ៉ាងច្រើននៅលើខ្សែបន្ទាត់ តាមដែលលោកអ្នកប្រាថ្នា។




**ឬ** ### នៅក្រោមខ្សែបន្ទាត់

ប្រសិនបើលោកអ្នកជ្រើសរើសបោះឆ្នោតនៅក្រោមខ្សែបន្ទាត់ លោកអ្នកចាំបាច់**ត្រូវដាក់លេខឲ្យបានយ៉ាងតិច 12 ប្រអប់** ចាប់ពី 1 ទៅ 12 ។ សម្រាប់បេក្ខជនម្នាក់ៗ ទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក។ លោកអ្នកអាចបន្តដាក់លេខទៅតាមលំដាប់នៃជម្រើសរបស់លោកអ្នក នៅក្នុងប្រអប់យ៉ាងច្រើននៅក្រោមខ្សែបន្ទាត់ តាមដែលលោកអ្នកប្រាថ្នា។




សន្លឹកឆ្នោតគំរូ

**សូមកុំខ្វល់ព្រួយអ្វីឡើយប្រសិនបើលោកអ្នកបំពេញខុស។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតមួយផ្សេងទៀត ហើយចាប់ផ្តើមបំពេញម្តងទៀត។**

តើលោកអ្នកបានដឹងឬទេថា លោកអ្នកអាចហាត់បោះឆ្នោតនៅតាមវិបសៃថ៍ AEC? សូមចូលទៅកាន់ **www.aec.gov.au/practise-voting**

## តើមានអ្វីកើតឡើងនៅកន្លែងបោះឆ្នោត?

1. មន្ត្រីជំនួយការបោះឆ្នោតនឹងសួរឈ្មោះពេញ និងអាសយដ្ឋានរបស់លោកអ្នក ហើយថាតើលោកអ្នកបានបោះឆ្នោតហើយឬនៅ នៅក្នុងការបោះឆ្នោតនេះ។ គេនឹងគូសឈ្មោះរបស់លោកអ្នកចេញពីបញ្ជីបោះឆ្នោត។



2. លោកអ្នកនឹងបានទទួលសន្លឹកឆ្នោតពីរសន្លឹក – សន្លឹកឆ្នោតពណ៌បៃតង គឺសម្រាប់សភាតំណាងរាស្ត្រ ហើយសន្លឹកឆ្នោតពណ៌សគឺសម្រាប់ព្រឹទ្ធសភា។



3. **សូមអានសេចក្តីណែនាំដែលមានចុះនៅលើសន្លឹកឆ្នោតទាំងពីរដោយប្រុងប្រយ័ត្ន។** ស្នើសុំជំនួយពីមន្ត្រីជំនួយការបោះឆ្នោត ប្រសិនបើលោកអ្នក មិនច្បាស់ប្រាកដ។



4. ពេលណាលោកអ្នកបានធ្វើចប់ហើយ សូមបត់សន្លឹកឆ្នោតរបស់លោកអ្នក ហើយដាក់សន្លឹកឆ្នោតទាំងនោះទៅក្នុងប្រអប់ឆ្នោតត្រឹមត្រូវ។

## សណ្ឋានផ្សេងទៀតនៃសេចក្តីណែនាំនេះ

លោកអ្នកអាចទាញយកទម្រង់ផ្សេងៗនៃសេចក្តីណែនាំនេះ ដូចជាសម្លេង និងការបោះពុម្ពជាអក្សរធំ នៅត្រង់ **www.aec.gov.au** ។ អក្សរសម្រាប់មនុស្សខ្វាក់ក៏មានផ្តល់ជូនដែរតាមការស្នើសុំ ដោយហៅទូរស័ព្ទលេខ 13 23 26 ។

ប្រសិនបើលោកអ្នកថ្លង់ ឬមានពិការភាពលើការស្តាប់ ឬនិយាយ សូមទាក់ទងមកយើងខ្ញុំតាមរយៈសេវាកម្មបញ្ជូនបន្ត National Relay Service (NRS) ៖

- អ្នកប្រើប្រាស់ TTY សូមហៅទូរស័ព្ទលេខ 13 36 77 ហើយស្នើសុំលេខ 13 23 26 ។
- អ្នកប្រើប្រាស់ Speak and Listen (និយាយ និងស្តាប់) សូមហៅទូរស័ព្ទលេខ 1300 555 727 ហើយស្នើសុំលេខ 13 23 26 ។
- អ្នកប្រើប្រាស់ការបញ្ជូនបន្តតាមអ៊ីនធើណិត សូមតភ្ជាប់ទៅ NRS ហើយស្នើសុំលេខ 13 23 26 ។

## ព័ត៌មានជាភាសាផ្សេងៗ

សណ្ឋានបកប្រែនៃសេចក្តីណែនាំនេះ អាចទាញយកបានពី **www.aec.gov.au/translated** ។

## សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

សម្រាប់ព័ត៌មានអំពីការបោះឆ្នោតជាភាសាខ្មែរ សូមទូរស័ព្ទលេខ 1300 720 134 ។

**ការបោះឆ្នោតគឺជាការសំខាន់ចាំបាច់ដោយខានពុំបានសម្រាប់ពលរដ្ឋអូស្ត្រាលីអាយុចាប់ពី១៨ឆ្នាំឡើងទៅ។** ប្រសិនបើលោកអ្នកមិនបោះឆ្នោតទេ លោកអ្នកអាចទទួលការកាត់ទោស។

**ប្រសិនបើលោកអ្នកបោះឆ្នោតច្រើនជាងមួយដង នេះគឺជាបទល្មើសព្រហ្មទណ្ឌ។**

17_0919

**www.aec.gov.au** 13 23 26

AEC Australian Electoral Commission

Authorised by the Electoral Commissioner, Canberra.